# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

TONLE SAP AUTHORITY
អាជ្ញាធរទន្លេសាប

លេខ :....០៨៣.....អទស

# សេចក្តីសម្រេច
## ស្តីពី
## ការបែងចែកភារកិច្ច និងការទទួលខុសត្រូវ
## របស់ថ្នាក់ដឹកនាំ អាជ្ញាធរទន្លេសាប

## រដ្ឋមន្ត្រី ក្រសួងធនធានទឹក និងឧតុនិយម
## និងជា ប្រធានអាជ្ញាធរទន្លេសាប

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញព្រះរាជក្រមលេខ ០៦នស/៩៤ ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១០/២៥៨ ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១០ ស្តីពីការកែសម្រួលមាត្រា ៣ មាត្រា ៥ មាត្រា ៦ មាត្រា ៩ មាត្រា ១០ និងមាត្រា ១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ ចុះថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប
- បានឃើញប្រកាសលេខ ០២៥ អទស ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋានក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប
- យោងតាមការចាំបាច់របស់អាជ្ញាធរទន្លេសាប ។

## សម្រេច

**ប្រការ ១ ៖** កំណត់របៀបរបបការងារ និងបែងចែកភារកិច្ចជូនឯកឧត្តមប្រធាន អនុប្រធាន អគ្គលេខាធិការ និងអគ្គលេខាធិការរង នៃអាជ្ញាធរទន្លេសាប សំដៅធានាការអនុវត្តច្បាប់ បទដ្ឋានគតិយុត្ត និងដឹកនាំកិច្ចការទូទៅនៅក្នុងអាជ្ញាធរទន្លេសាប ។

**ប្រការ ២ ៖** ប្រធានអាជ្ញាធរទន្លេសាប ទទួលខុសត្រូវដឹកនាំការងាររួមរបស់អាជ្ញាធរទន្លេសាប ។

**ប្រការ ៣ ៖** ត្រូវបានបែងចែក និងប្រគល់ភារកិច្ចជូនអនុប្រធាន អគ្គលេខាធិការ និងអគ្គលេខាធិការរង ដើម្បីជួយឯកឧត្តមប្រធានអាជ្ញាធរទន្លេសាប ដូចខាងក្រោម ៖

១.ឯកឧត្តម **លឹម ពុយ** អនុប្រធានអាជ្ញាធរទន្លេសាប ជួយឯកឧត្តមប្រធានលើការងារបច្ចេកទេស និងការសិក្សាស្រាវជ្រាវ ។

២.ឯកឧត្តម **ហ៊ើល គុនី** អនុប្រធានអាជ្ញាធរទន្លេសាបជួយឯកឧត្តមប្រធានលើការងាររដ្ឋបាល ។

៣.ឯកឧត្តម **ស៊ិន ទិសិទ្ធ** អគ្គលេខាធិការអាជ្ញាធរទន្លេសាប ទទួលបន្ទុកដឹកនាំការងារប្រចាំថ្ងៃរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ។

៤.ឯកឧត្តម **ម៉ៅ ហាក់** អគ្គលេខាធិការរងអាជ្ញាធរទន្លេសាប ទទួលជួយអគ្គលេខាធិការ លើការងារ នៃនាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ ។

៥.ឯកឧត្តម **ខុច មាស** អគ្គលេខាធិការរងអាជ្ញាធរទន្លេសាប ទទួលជួយអគ្គលេខាធិការ លើការងារ នៃនាយកដ្ឋានធនធានធម្មជាតិ និងនាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស ។

៦.ឯកឧត្តម **សរ គីមសាន្ត** អគ្គលេខាធិការរងអាជ្ញាធរទន្លេសាប ទទួលជួយអគ្គលេខាធិការលើការងារ នៃនាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ ។

**ប្រការ ៤ ៖** ក្រៅពីភារកិច្ច និងការទទួលខុសត្រូវ ដូចបានកំណត់ខាងលើ អនុប្រធាន អគ្គលេខាធិការ និងអគ្គលេខាធិការរងគ្រប់រូប ត្រូវបំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ភារកិច្ចរបស់ ឯកឧត្តមប្រធាន ។

**ប្រការ ៥ ៖** អំពីរបៀបរបបធ្វើការ និងទំនាក់ទំនងការងារ ក្នុងអាជ្ញាធរទន្លេសាប មានដូចខាងក្រោម ៖

- រាល់ឯកសារ លិខិតស្នាមចេញ-ចូល ទាំងផ្ទៃក្នុង និងខាងក្រៅ ត្រូវឆ្លងកាត់ច្រកចេញចូលតែមួយ គឺការិយាល័យរដ្ឋបាល នៃនាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ ហើយត្រូវរៀបចំលើកកំណត់បង្ហាញរឿង ដាក់ជូនថ្នាក់ដឹកនាំទៅតាមឋានានុក្រម ធ្វើការពិនិត្យ ផ្តល់យោបល់ មុននឹងដាក់ជូនឯកឧត្តមប្រធានពិនិត្យ និងសម្រេច ។
- នៅពេលអវត្តមាន អគ្គលេខាធិការ ត្រូវផ្ទេរសិទ្ធិជូនអគ្គលេខាធិការរងណាម្នាក់ឲ្យទទួលដឹកនាំការងារប្រចាំថ្ងៃរបស់អគ្គលេខាធិការដ្ឋាន ។ អគ្គលេខាធិការរងដែលទទួលបានការផ្ទេរសិទ្ធិ ត្រូវទទួលខុសត្រូវលើកិច្ចការ ដែលខ្លួនបានសម្រេចក្នុងរយៈពេលទទួលសិទ្ធិដឹកនាំការងារ និងត្រូវរាយការណ៍ អំពីកិច្ចការទាំងនោះ ជូនអគ្គលេខាធិការ ពេលមានវត្តមានវិញ ។

**ប្រការ ៦ ៖** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧ ៖** រដ្ឋលេខាធិការទទួលបន្ទុក អនុប្រធាន អគ្គលេខាធិការ អគ្គលេខាធិការរង និងប្រធាននាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរទន្លេសាប ត្រូវទទួលបន្ទុកអនុវត្តតាមសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃចន្ទ ៣ កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែឧសភា ឆ្នាំ ២០១៩

**ប្រធាន**

**លឹម គានហោ**

**កន្លែងទទួល ៖**

- ក្រសួងធនធានទឹក និងឧតុនិយម
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
- ដូចប្រការ ៧
- ឯកសារ-កាលប្បវត្តិ